# ទិស៦

## Disa: directions

បុគ្គលប្រភេទផ្សេងៗដែលយើងត្រូវទាក់ទងនិងមានសម្ព័ន្ធខាងផ្នែកសង្គមដូចទិសដែលនៅជុំវិញខ្លួន
Roles that each individual with different position should act to each other as the directions we have to turn towards

**១- បុរត្ថិមទិស** (ទិសខាងមុខ គឺទិសខាងកើត បានដល់មាតាបិតា ព្រោះជាទិសមានឧបការៈដល់យើងមុន -Puratthima-disa: parents as the east or the direction in front

**ក) បុត្រធីតាគប្បីបម្រុងរក្សាមាតាបិតាដែលជាទិសខាងកើតដោយស្ថាន៥យ៉ាងគឺ :**

**១)** លោកចិញ្ចឹមយើងមកហើយ យើងត្រូវចិញ្ចឹមលោកវិញ

**២)** ជួយធ្វើកិច្ចការងាររបស់លោក

**៣)** តម្រង់វង្សត្រកូល រក្សាវង្សត្រកូលឱ្យល

**៤)** ប្រព្រឹត្តខ្លួនឱ្យសមជាអ្នកទទួលមរតក

**៥)** ពេលលោករំលាយខន្ធទៅធ្វើបុណ្យឧទ្ទិសឱ្យលោក

**A- In five ways a child should minister to his parents as the eastern quarter(saying to himself)**

1. Having been supported by them I will support them in my turn.
2. I will do their work for them.
3. I will keep up the honour and the traditions of my family.
4. I will make myself worthy of my heritage.
5. I will make offerings, dedicating merit to them after their death

**ខ) មាតាបិតាសង្គ្រោះបុត្រធីតាដោយស្ថាន៥យ៉ាង**

**១)** ហាមមិនឱ្យធ្វើបាប

**២)** ឱ្យតាំងនៅក្នុងអំពើល្អ

**៣)** ឱ្យសិក្សារៀនសូត្រ

៤) រកគូស្រករដែលសមគួរឱ្យ

៥) ប្រគល់ទ្រព្យសម្បត្តិឱ្យក្នុងឱកាសដ៏សមគួរ

**B- In five ways his parents, thus served as the eastern quarter, show their love for him(saying to himself)**

1. They keep him back from evil.
2. They train him in virtue.
3. They have him taught arts and sciences.
4. They arrange for his marriage to a suitable wife.
5. They hand over his inheritance to him in due time.

**២-ទក្ខិណាទិស** (ទិសខាងស្តាំ គឺខាងត្បូង បានដល់គ្រូបាធ្យាយ ព្រោះជាទក្ខិណេយ្យបុគ្គលគួរដល់ការបូជា -Dakkhina-disa: teachers as the south or the direction in the right

**ក- សិស្សគប្បីបម្រុងគ្រូបាធ្យាយ ជាទិសខាងស្តាំដោយស្ថាន៥យ៉ាង**

១) ក្រោកឈរទទួលគ្រូ

២) ចូលទៅបំរើគ្រូ

៣) តាំងចិត្តរៀនសូត្រ

៤) ជួយធ្វើកិច្ចការនៅពេលគ្រូមានរវល់

៥) សិក្សារៀនសូត្រដោយគោរព

**A- In five ways a pupil should minister to his teachers as the southern quarter:**

1. by rising to receive them.
2. by waiting upon them.
3. by eagerness to learm.
4. by personal service.
5. by attentively learning the arts and sciences.

**ខ) គ្រូគប្បីសង្គ្រោះសិស្សដោយស្ថាន ៥ យ៉ាង**

១) បង្រៀនសិស្សឱ្យទៅជាមនុស្សល្អ

២) បង្រៀនឱ្យយល់ច្បាស់

៣) បង្រៀនឱ្យអស់ចំណេះ មិនលាក់លៀមទុក

៤) លើកតម្កើងសិស្សក្នុងពួកមិត្ត និងមន្ត្រី

៥) ជួយការពារក្នុងទិសទាំងពួង(បង្រៀនឱ្យសិស្សចេះចិញ្ចឹមនិងថែរក្សាខ្លួន នៅគ្រប់ទិសទី និងគ្រប់បរិដ្ឋានទាំងអស់

**B- In five ways his teachers, thus served as the southerm quarter, show their love for him:**

1. They train him so that he is well-trained.
2. They train him in such a way that he understands and remembers well what he has been taught.
3. They thoroughly instruct him in the lore of every art.
4. They introduce him to his friends and companions.
5. They provide for his safety and security in every quarter.

**៣. បច្ចិមទិស** (ទិសខាងក្រោយ គឺទិសខាងលិចបានដល់បុត្រភរិយា ព្រោះជាប់ទាក់ទងដូចជាជន្ទល់ខ្នង ជាកម្លាំងគាំទ្រនៅពីខាងក្រោយ -Pacchima-disa: wife and children as the west or the direction behind

**ក) ស្វាមីសង្គ្រោះភរិយាដោយស្ថាន៥យ៉ាង**

១) លើកតម្កើងនិងឱ្យកិត្តិយសសមនឹងឋានៈជាភរិយា

២) មិនមើលងាយភរិយា

៣) មិនក្បត់ចិត្តភរិយា

៤) ប្រគល់អំណាចក្នុងផ្ទះឱ្យទៅភរិយា

៥) រកគ្រឿងប្រដាប់តាក់តែងកាយតាមកាលសម័យឱ្យទៅភរិយា

**A- In five ways a husband should serve his wife as the western quarter:**

1. by honouring her.
2. by being courteous to her.
3. by being faithful to her.
4. by handing over authority to her.
5. by providing her seth ornaments.

**ខ) ភរិយាអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាង**

១) ចាត់ចែងការងារផ្ទះឱ្យរៀបរយ

២) សង្គ្រោះញាតិមិត្រខាងស្វាមីដោយល្អ

៣) មិនក្បត់ចិត្តស្វាមី

៤) រក្សាទ្រព្យសម្បត្តិដែលស្វាមីរកបានមកហើយ

៥) ឧស្សាហ៍ព្យាយាមក្នុងកិច្ចការទាំងពួង

**B- In five ways his wife, thus served as the western quarter, shows her love for him.**

1. The household affairs are to be well managed.
2. She should affairs are to be well managed.
3. She should be faithful to him.
4. She should take care of the goods he brings home.
5. She should be skilful and industrious in all her duties.

**៤. ឧត្តរទិស** (ទិសខាងឆ្វេង គឺទិសខាងជើង បានដល់មិត្តសំឡាញ់យើង ព្រោះជាអ្នកជួយយើងឱ្យឆ្លងរួចផុតពីឧបសគ្គភ័យអន្តរាយ និងជាកម្លាំងគាំទ្រឱ្យសម្រេចតាមគោលបំណង. Uttara-disa: friends and companions as the north or the direction in the left

**ក) បុគ្គលគប្បីសង្គ្រោះមិត្តសំទឡាញ់ដោយស្ថាន៥យ៉ាង**

**១)** អាណិតអាសូរនិងចែករំលែកដល់មិត្ត

**២)** និយាយស្ដីដោយមេត្រីភាព

**៣)** ជួយសង្គ្រោះគ្នា

**៤)** មានខ្លួនស្មើ គឺរួមសុខទុក្ខជាមួយគ្នា

**៥)** ទៀងត្រង់ដល់គ្នានឹងគ្នា

**A- In five ways a clansman should serve his friends and associates as the northern quarter:**

1. by generosity.
2. by kind words.
3. by helping them and acting for their welfare.
4. by putting them on equal terms.
5. by being sincere to them.

**ខ) មិត្តសំទឡាញ់គប្បីសង្រ្គោះវិញដោយស្ថាន៥យ៉ាង**

**១)** ពេលមិត្តសំទឡាញ់ប្រមាទ ជួយរក្សាការពារ

**២)** ពេលមិត្តសំទឡាញ់ប្រមាទ ជួយរក្សាការពារទ្រព្យសម្បត្តិរបស់មិត្តសំឡាញ់

**៣)** ពេលមានអាសន្នផ្តល់ទីពំនឹងបាន

**៤)** មិត្តលះបង់ចោលក្នុងពេលមានអាសន្នអន់ក្រ

**៥)** រាប់អានរហូតដល់វង្សញាតិរបស់មិត្តសំឡាញ់

**B- In five ways his friends and associates, thus served as the vorthern quarter,show their love for him:**

1. They protect him when he is careless.
2. They guard his property when he is careless.
3. They are a refuge for him when he is in danger.
4. They do not leave him in his troubles.
5. They show due respect to other members of his family.

**៥. ហេដ្ឋិមទិស** (ទិសខាងក្រោម បានដល់អ្នកបំរើ និងកម្មករ ព្រោះជាអ្នកជួយធ្វើការងារផ្សេងៗជាគ្រឹះកម្លាំងឱ្យ។ Hetthima-disa: servants and workmen as the nadir

**ក) ចៅហ្វាយនាយគួរបម្រុងបុគ្គលិក អ្នកបំរើ និងកម្មករ ដោយស្ថាន៥យ៉ាង**

**១)** ចាត់ចែងការងារឱ្យធ្វើតាមកម្លាំងដែលអាចធ្វើបាន

**២)** ឱ្យថ្លៃឈ្នួលសមគួរទៅតាមការងារ កម្លាំង និងការរស់នៅ

**៣)** ជួយមើលថែរក្សានៅពេលមានជម្ងឺ

**៤)** ពេលបានរបស់ប្លែកៗ ក៏យកមកចែករំលែកឱ្យ

**៥)** ចាត់ឱ្យមានថ្ងៃសំរាកសមគួរតាមឱកាស

**A- In five ways a master should serve his servants and orkmen as the lower quarter:**

1. by assinging them work according to their strength.
2. by giving them due food and wages.
3. by caring for them in sickness.
4. by sharing with them unusual luxuries.
5. by giving them holidays and leave at suitable times.

**ខ) បុគ្គលិក អ្នកបំរើ និងកម្មករសង្គ្រោះចៅហ្វាយនាយដោយស្ថាន៥យ៉ាង**

១) ចាប់ផ្តើមធ្វើការងារមុនចៅហ្វាយនាយ

២) សំរាកការងារក្រោយចៅហ្វាយនាយ

៣) កាន់យកតែរបស់ណាដែលចៅហ្វាយនាយឱ្យ

៤) ធ្វើការងារឱ្យស្អាតរៀបរយ និងកាន់តែល្អឡើង

៥) នាំកិត្តិស័ព្ទរបស់ចៅហ្វាយទៅផ្សព្វផ្សាយ

**B- In five ways his servants and workmen, thus served as the lower quarter, show their love for him:**

1. They get up to work before him.
2. They rest after him.
3. They take only what is given to them.
4. They do their work well.
5. They spread about his praise and good name.

**៦. ឧបរិមទិស** (ទិសខាងលើបានដល់សមណព្រាហ្មណ៍ គឺព្រះសង្ឃ ព្រោះជាអ្នកខ្ពង់ខ្ពស់ដោយគុណធម៌ និងជាអ្នកដឹកនាំផ្លូវចិត្តគំនិត -Uparima-disa: monks as the zenith

**ក) គ្រហស្ថសង្គ្រោះព្រះសង្ឃដោយស្ថាន៥យ៉ាង**

១) នឹងធ្វើអ្វី ក៏ធ្វើដោយមេត្តាចំពោះលោក

២) នឹងនិយាយអ្វី ក៏និយាយដោយមេត្តាចំពោះលោក

៣) នឹងគិតអ្វី ក៏គិតដោយមេត្តាចំពោះលោក

៤) ទទួលរាក់ទាក់លោកដោយសេចក្តីពេញចិត្ត

៥) ទំនុកបំរុងលោកដោយបច្ច័យ៤

**A- In five ways a clansman should serve monds and Brahmins as the upper quarter:**

1. by kindly acts.
2. by kindly words.
3. by kindly thoughts.
4. by keeping open hous to them.
5. by supplying them with their material needs.

**ខ) ព្រះសង្ឃសង្គ្រោះគ្រហស្ថដោយស្ថាន ៦ យ៉ាង**

**១)** ហាមប្រាមគ្រហស្ថមិនឱ្យធ្វើអាក្រក់

**២)** ប្រាប់គ្រហស្ថឱ្យតាំងនៅក្នុងសេចក្ដីល្អ

**៣)** អនុគ្រោះគ្រហស្ថដោយសេចក្ដីប្រាថ្នាល្អ

**៤)** ឱ្យគ្រហស្ថបានស្ដាប់នូវរឿងដែលមិនធ្លាប់ស្ដាប់

**៥)** ធ្វើឱ្យគ្រហស្ថយល់ច្បាស់ក្នុងរឿងដែលធ្លាប់បានស្ដាប់ហើយ

**៦)** ប្រាប់ផ្លូវស្ធគ៌ គឺមានមាគ៌ាជីវិតដែលមានសេចក្ដីសុខចំរើនដល់គ្រហស្ថ

**B- In six ways the monks, thus served as the upper quarter, show thier love for him:**

1. They keep him back from evil.
2. They encourage him to do good.
3. They feel for him with kindly thoughts.
4. They teach him what he has not heard before.
5. They correct and clarity what he has learnt.
6. They show him the way to heaven

អ្នកប្រតិបត្តិដូចបានពោលមកនេះ មានឈ្មោះថារក្សាការពារខ្លួនសព្វគ្រប់ទិស ជាអ្នកក្សេមក្សាន្ត មិនមានអន្តរាយឡើយ

**គម្ពីរសុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ**